**អភិបូជាបុណ្យរោយផេះ**

**នៅព្រះសហគមន៍ពោធិ៍ចិនតុង**

**ភ្នំពេញ ថ្ងៃទី២ ខែមីនា ឆ្នាំ២០២២**

**"មិនត្រូវនឿយណាយនឹងប្រព្រឹត្តអំពើល្អ"**

**អត្ថបទទី១៖ យ៉ូអែល ២,១២-១៨**

ចូរនាំគ្នាវិលមករកយើង ដោយស្មោះអស់ពីចិត្ត។ យអ ២,១២

**អត្ថបទទី២៖ កូរិនថូសទី២ ៥,២០-៦,២**

គ្រាដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យ គឺឥឡូវនេះហើយ!។ ២ករ ៦,២

**ដំណឹងល្អ៖ ម៉ាថាយ ៦,១-៦.១៦-១៨**

កុំធ្វើបុណ្យទានកនៅមុខមនុស្សម្នា ដើម្បីឲ្យតែគេឃើញនោះឡើយ។ មថ ៦,១

បងប្អូនជាទីស្រឡាញ់

យើងបានស្តាប់នៅក្នុងអត្ថបទទី២ "**គ្រាដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យគឺឥលូវនេះហើយ ថ្ងៃដែលព្រះជាម្ចាស់សង្គ្រោះពិភពលោកគឺឥលូវនេះហើយ**"។ មានន័យថា មិនមែនថ្ងៃស្អែក មិនមែនមួយឆ្នាំទៀត ប៉ុន្តែឥលូវនេះហើយ ថ្ងៃនេះដែលយើងចូលនៅក្នុងរដូវ៤០ថ្ងៃ យើងដឹងថារដូវ៤០ថ្ងៃជាពេលវេលាមួយយ៉ាងពិសេស។ ដូចសម្តេចប៉ាបបានរំលឹកដល់យើងទាំងអស់គ្នា ដើម្បីសាបព្រោះអំពើល្អ "**យើងមិនត្រូវនឿយណាយនឹងប្រព្រឹត្តអំពើល្អឡើយ ត្បិតប្រសិនបើយើងមិនបាក់ទឹកចិត្តទេនោះ ដល់ពេលកំណត់យើងច្រូតបានផលជាមិនខាន ហេតុនេះពេលយើងមានឱកាសនៅឡើយ យើងត្រូវតែប្រព្រឹត្តអំពើល្អចំពោះមនុស្សទាំងអស់**"។ ឥលូវនេះជាពេលវេលាដើម្បីឆ្លៀតឱកាស ដើម្បីចូលនៅក្នុងទំនាក់ទំនងសាជាថ្មីជាមួយព្រះជាម្ចាស់។

យើងបានស្តាប់នៅក្នុងអត្ថបទទី១ "**ចូរនាំគ្នាវិលមករកយើង ដោយស្មោះអស់ពីចិត្ត ប្រសិនបើអ្នករាល់គ្នាប្រែចិត្តគំនិតដូច្នេះ ប្រហែលជាព្រះអង្គមិនដាក់ទោសអ្នករាល់គ្នាទេមើលទៅ**"។ តាមពិតពេលវេលាដែលយើងចូលនៅពេលនេះ គឺជាពេលវេលាដើម្បីត្រឡប់មកវិញទៅរកព្រះជាម្ចាស់

អស់ពីដួងចិត្ត អស់ពីស្មារតី អស់ពីជំនឿ អស់ពីសេចក្ដីស្រឡាញ់ ដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតថ្មី។ តាមពិត នៅក្នុងមួយឆ្នាំយើងមានឱកាសច្រើន ដើម្បីកែប្រែចិត្តគំនិត ប៉ុន្តែយើងមានពេលវេលាដែលព្រះសហគមន៍ប្រទានដល់យើង។ ៤០ថ្ងៃ ដើម្បីឲ្យយើងត្រឡប់មករកព្រះជាម្ចាស់នៅក្នុងចិត្តរបស់យើង ដើម្បីទៅជាមនុស្សថ្មីដែលជាប់ជាមួយព្រះជាម្ចាស់ដែលបានបង្កើតយើង។ ឆ្នាំនេះសម្ដេចប៉ាបអញ្ជើញយើង កុំឲ្យយើងអស់កម្លាំង កុំឲ្យយើងនឿយណាយ ឲ្យយើងខិតខំអស់ពីសមត្ថភាព ដើម្បីសាបព្រោះអំពើល្អ។ សាបព្រោះ ដើម្បីឲ្យនៅក្នុងជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ យើងយកចិត្តទុកដាក់ធ្វើសេចក្ដីល្អដល់បងប្អូនឯទៀតៗ ដើម្បីយើងធ្វើដំណើរនៅក្នុងសង្គមបច្ចុប្បន្ននេះ។ ឲ្យយើងជាគ្រីស្តបរិស័ទ ទៅជាសាក្សីនៃព្រះហឫទ័យរបស់ព្រះជាម្ចាស់ដ៏ពិតប្រាកដ ដោយប្រព្រឹត្តអំពើល្អដល់បងប្អូនឯទៀតៗ។

យើងដឹងហើយ អ្នកដែលជាកសិករនៅពេលយើងសាបព្រោះយ៉ាងល្អ ពេលយើងរៀបចំដីយើងយ៉ាងល្អ ពេលយើងថែរក្សាដីនិងដំណាំយើងល្អ យើងដឹងថាយើងមានផ្លែបានយ៉ាងច្រើនសម្រាប់ចិញ្ចឹមជីវិតរបស់យើងផ្ទាល់។ សម្រាប់យើងក៏ដូចគ្នាដែរ ប្រសិនបើយើងយកចិត្តទុកដាក់ដើម្បីសាបព្រោះអំពើល្អ ប្រសិនបើយើងយកចិត្តទុកដាក់រៀបចំចិត្តគំនិតរបស់យើងយ៉ាងល្អ ប្រសិនបើយើងយកចិត្តទុកដាក់ថែរក្សាសេចក្ដីស្រឡាញ់ ជំនឿ សេចក្ដីសង្ឃឹមរបស់យើងទៅលើព្រះជាម្ចាស់យ៉ាងល្អ ជីវិតរបស់យើងអាចមានផ្លែយ៉ាងច្រើន ដើម្បីកសាងព្រះសហគមន៍ ដើម្បីកសាងពិភពថ្មី។ នៅឆ្នាំនេះ ដែលយើងចេញពីកូវីដ-១៩ យើងបានឆ្លងកាត់ទុក្ខលំបាកយ៉ាងច្រើន នៅឆ្នាំនេះដែលយើងកំពុងភ័យដោយយើងឃើញសង្គ្រាមដែលកើតឡើងនៅក្នុងទ្វីបអឺរ៉ុប។ ទោះបីឆ្ងាយក៏ដោយ យើងដឹងថាសព្វថ្ងៃពិភពរបស់យើងជាពិភពមួយ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនៅក្នុងគ្រប់ទីកន្លែង។ ហេតុនេះហើយ ពេលមានសង្គ្រាមមួយកើតឡើងនៅកន្លែងណាមួយក៏មានឥទ្ធិពលសម្រាប់យើងទាំងអស់គ្នានៅប្រទេសទាំងអស់។

ហេតុនេះហើយ យើងត្រូវការនឹកឃើញគ្រប់ពេលវេលា ដូចសម្ដេចប៉ាបបានរំលឹកនៅក្នុងសារលិខិតរបស់ព្រះអង្គ សម្រាប់រដូវអប់រំពិសេសនេះ ឲ្យយើងយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងទទួលព្រះអំណោយទានមួយយ៉ាងពិសេស គឺព្រះអំណោយទានដែលមកពីព្រះជាម្ចាស់ផ្ទាល់ យើងទទួលកម្លាំង យើងទទួលសេចក្ដីស្រឡាញ់ យើងទទួលសមត្ថភាព ដើម្បីទៅជាសហការីរបស់ព្រះជាម្ចាស់ដើម្បីបង្កើតពិភពថ្មី។ តាមពិត ប្រសិនបើព្រះជាម្ចាស់អត់មានយើងទេ ព្រះជាម្ចាស់ក៏ប្រហែលធ្វើមិនកើតទេ ព្រះជាម្ចាស់មានយើងដែលជាបុត្រាបុត្រីរបស់ព្រះអង្គ ដើម្បីឲ្យសេចក្ដីស្រឡាញ់ យុត្តិធម៌ ជាពិសេសសុខសន្តិភាពបានកើតឡើងនៅលើផែនដីនេះឥលូវនេះ។ ដូចសន្តប៉ូលបានរំលឹក ឥលូវនេះមិនមែនថ្ងៃស្អែក មិនមែនឆ្នាំក្រោយ ប៉ុន្តែឥលូវនេះ។ ហេតុនេះហើយ ចាប់ពីពេលនេះតទៅយើងត្រូវការភ្ញាក់ដែរ ដើម្បីរស់នៅក្នុងសេចក្ដីស្រឡាញ់ និងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។

យើងមានផ្លូវ៣ ផ្លូវទី១គឺយើងមិនត្រូវនឿយណាយនឹងការអធិដ្ឋានឡើយ ទី២យើងមិនត្រូវនឿយណាយនឹងការលុបបំបាត់អំពើអាក្រក់ដែលចេញពីក្នុងជីវិតរបស់យើងឡើយ និងទី៣យើងមិននឿយណាយនឹងប្រព្រឹត្តអំពើល្អ ដោយធ្វើកិច្ចការសប្បុរសជាក់ស្តែងចំពោះបងប្អូនឯទៀតៗនោះឡើយ។

បងប្អូនជាទីស្រឡាញ់ យើងមានផ្លូវ៣នៅក្នុងរដូវ៤០ថ្ងៃ ថ្ងៃនេះយើងត្រូវការសម្រេចចិត្តតើយើងត្រូវការធ្វើអ្វីខ្លះដើម្បី**ទី១** អធិដ្ឋានថែមទៀត។ នៅពេលយើងអធិដ្ឋាន យើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅពេលយើងអធិដ្ឋានយើងទទួលកម្លាំងពីព្រះអង្គផ្ទាល់។ ពេលយើងអធិដ្ឋាន យើងទូលអង្វរព្រះជាម្ចាស់ឲ្យព្រះអង្គណែនាំយើងឱ្យកែប្រែចិត្តគំនិត ដើម្បីឲ្យព្រះអង្គណែនាំឲ្យពិភពលោករបស់យើងរកឃើញសេចក្តីស្រឡាញ់ដ៏ពិតប្រាកដ និងសុខសន្តិភាព។ ដូច្នេះ នៅក្នុងរដូវ៤០ថ្ងៃនេះ ឲ្យយើងគិតពិចារណា ខ្ញុំជាគ្រីស្តបរិស័ទ ខ្ញុំជាសាវ័ករបស់ព្រះយេស៊ូ ខ្ញុំធ្វើដូចម្តេចដើម្បីយកពេលវេលាថែមដើម្បីអធិដ្ឋាន។ អធិដ្ឋានដោយចូលនៅក្នុងព្រះវិហារ អធិដ្ឋានផ្តាំ អធិដ្ឋានដោយគោរពព្រះកាយព្រះគ្រីស្ត អធិដ្ឋានដោយស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ អធិដ្ឋានដោយសន្ទនា។ សន្ទនាធម្មតាជាមួយព្រះជាម្ចាស់ ដែលស្រឡាញ់យើងនៅក្នុងគ្រប់ពេលវេលា។

**ទី២** ឲ្យយើងយកចិត្តទុកដាក់ដើម្បីលុបបំបាត់អំពើអាក្រក់ ដែលចេញពីក្នុងជីវិតរបស់យើង។ អំពើបាបដែលយើងមាន ទុក្ខលំបាកដែលរារាំងសេចក្តីស្រឡាញ់របស់យើងចំពោះបងប្អូនឯទៀតៗ ឲ្យយើងទៅជាមនុស្សថ្មីដោយកែប្រែចិត្តគំនិត។ ដោយតមអាហារ ដោយតមអំពើអាក្រក់ដែលយើងធ្លាប់ធ្វើ ដោយយកចិត្តទុកដាក់ ដើម្បីបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតៗសាជាថ្មី។ សម្តេចប៉ាបរំលឹក នៅក្នុងសារលិខិតរបស់ព្រះអង្គថា នៅក្នុងកូវីដ-១៩ យើងបានបង្កើតទំនាក់ទំនងក្លែងក្លាយតាមបណ្តាញទំនាក់ទំនងសង្គមដែលយើងមាន។ ប៉ុន្តែ ពេលវេលានេះជាពេលវេលា ដើម្បីយកចិត្តទុកដាក់បង្កើតទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកសាជាថ្មី។ ឲ្យយើងមើលឃើញបងប្អូន ជាបងប្អូនយើងដ៏ពិតប្រាកដ ដែលជាអំណោយទានដែលយើងទទួលពីព្រះជាម្ចាស់ផ្ទាល់។ ឲ្យយើងខិតខំ ឲ្យយើងសម្រេចចិត្តថ្ងៃនេះ ឥលូវនេះ ដើម្បីលុបបំបាត់អំពើអាក្រក់ពីជីវិតរបស់យើងផ្ទាល់។

**ទី៣** ឲ្យយើងសម្រេចចិត្តឥលូវនេះ នៅពេលនេះ ឲ្យយើងធ្វើអំពើល្អ កិច្ចការល្អដល់បងប្អូនឯទៀតៗ កុំឲ្យយើងគិតថាអត់អីទេយើងមានពេលច្រើន។ នៅពេលយើងបានទទួលពេយផេះល្ងាចនេះ ដែលណែនាំឲ្យយើងនឹកឃើញយើងជាធូលី ប៉ុន្តែយើងត្រូវកែប្រែចិត្តគំនិតដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់សាជាថ្មី។ យើងធ្វើដូចម្តេច ដើម្បីមានអំពើល្អនៅក្នុងរដូវ៤០ថ្ងៃ អំពើល្អដល់អ្នកជិត

ខាង អំពើល្អដល់ឪពុកម្តាយ អំពើល្អដល់ពួកម៉ាក់របស់យើង អំពើល្អដែលយើងអាចនឹកឃើញ ដើម្បីឲ្យជីវិតរបស់យើងរស់នៅប្រកដដោយសេចក្ដីស្រឡាញ់ ដែលមកពីព្រះជាម្ចាស់ផ្ទាល់។

បងប្អូនជាទីស្រឡាញ់ ប្រសិនបើយើងអនុវត្តរបៀបហ្នឹង ប្រសិនបើយើងយកចិត្តទុកដាក់សាបព្រោះដោយអធិដ្ឋានផង ដោយលុបបំបាត់អំពើអាក្រក់របស់យើងចេញពីដួងចិត្តរបស់យើងផង ដោយធ្វើអំពើល្អទៅបងប្អូនឯទៀតៗផង នោះយើងដឹងថាយើងអាចរកឃើញផ្លែយ៉ាងច្រើន នៅក្នុងជីវិតរបស់យើង និងសម្រាប់ជីវិតរបស់បងប្អូនឯទៀតៗ។ នៅពេលយើងអនុវត្តនេះទាំងអស់ យើងអាចរស់នៅតាមរបៀបដែលលោកប៉ូលបានប្រកាស នៅក្នុងអត្ថបទទី២ដែលយើងបានស្តាប់ "**យើងជាទូតរបស់ព្រះគ្រីស្ត គឺដូចជាព្រះជាម្ចាស់មានព្រះបន្ទូលដាស់តឿនបងប្អូនតាមរយៈយើងដែរ**"។ យើងជាទូតរបស់ព្រះគ្រីស្ត នៅពេលយើងរស់នៅនៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់ នៅពេលយើងភ្ជាប់ជាមួយព្រះជាម្ចាស់នៅក្នុងសេចក្ដីស្រឡាញ់ នៅពេលយើងខិតខំកែប្រែចិត្តគំនិតដើម្បីទៅជាមនុស្សថ្មី នៅពេលយើងយកចិត្តទុកដាក់ធ្វើអំពើល្អដល់បងប្អូនឯទៀតៗ នៅពេលនោះយើងជាទូតរបស់ព្រះគ្រីស្តយ៉ាងជាក់ស្តែង។ យើងជាសាក្សីនៃជីវិតរបស់ព្រះជាម្ចាស់យ៉ាងជាក់ស្តែង ដែលណែនាំឲ្យបងប្អូនឯទៀតៗនៅក្នុងភូមិយើង នៅក្នុងសង្គមយើង នៅក្នុងព្រះសហគមន៍យើង អាចមើលឃើញវត្តមានរបស់ព្រះជាម្ចាស់។ ដោយសារ យើងប្រកាសមិនមែនតែដោយបបូរមាត់តែប៉ុណ្ណឹង ប៉ុន្តែយើងប្រកាសដោយកាយវិការ ដោយសំដី ដោយការងារដែលយើងធ្វើជាប្រចាំ។

បងប្អូនជាទីស្រឡាញ់ នៅពេលនេះយើងអធិដ្ឋានជាមួយសម្តេចប៉ាបៈ "*បពិតព្រះនាងម៉ារី ព្រះសង្គ្រោះបានចាប់កំណើតនៅក្នុងផ្ទៃព្រះនាង ព្រះនាងបានចងចាំហេតុការណ៍ទាំងអស់ ហើយថែទាំទាំងរិះគិតពិចារណានៅក្នុងដួងចិត្តទៀតផង។ សូមព្រះនាងប្រទានឲ្យយើងទទួលអំណោយទាន និងចិត្តស៊ូទ្រាំ និងបានរួមចិត្តស្និទ្ធជាមួយព្រះអង្គម្ចាស់ តាមរយៈព្រះមាតាព្រះអង្គ ដើម្បីឲ្យពេលវេលានៃការប្រែចិត្តគំនិតនេះ ទទួលផលនៃការសង្គ្រោះអស់កល្បជានិច្ចផង*"។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ

https://youtu.be/y1tT87twEko